USAID
FROM THE AMERICAN PEOPLE

WINROCK
INTERNATIONAL
Putting Ideas to Work




គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ ( CTIP II )

ចេញផ្សាយលេខ ៣ ខែមេសា-មិថុនា ឆ្នាំ២០១៤

## ការរស់ឡើងវិញពីដំណើរផ្លូវដ៏វែងឆ្ងាយ

ដោយសារភាពក្រីក្ររបស់ខ្លួន និងត្រូវបានមេខ្យល់បញ្ឆោតបញ្ចុះបញ្ចូលឲ្យជឿថា មានឱកាសការងារល្អ ក.ម ជាកសិករអាយុ ២៧ឆ្នាំម្នាក់ បានចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ២០០៨ ដើម្បីទៅធ្វើការនៅប្រទេសថៃ។ ក្រោយពេលឆ្លងព្រំដែន គាត់ត្រូវបានឃុំខ្លួនបញ្ជូនតាមទូកទៅកាន់ប្រទេសឥណ្ឌូនេស៊ី និងលក់ទៅឲ្យនិយោជកជនជាតិឥណ្ឌូនេស៊ីម្នាក់។ អស់រយៈពេល ៤ ឆ្នាំ គាត់រស់នៅដូចជាទាសករលើទូកនេសាទ។ ក.ម ត្រូវបានគំរាម និងបង្ខំឲ្យធ្វើការជាច្រើនម៉ោង ដោយទទួលបានអាហារមិនគ្រប់គ្រាន់។

ថ្ងៃមួយ ក.ម បានសុំលេខទូរស័ព្ទប៉ូលីសពីកម្មករទូកម្នាក់ទៀត។ គាត់ត្រូវបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជានៅដើមឆ្នាំ២០១៣។

នៅប្រទេសកម្ពុជា គាត់ត្រូវបានបញ្ជូនទៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ជាដៃគូរបស់គម្រោង CTIP II ក្រោមការឧបត្ថម្ភគាំទ្រថវិកាពី USAID ។ គាត់បានទទួលការប្រឹក្សាយោបល់ផ្លូវចិត្ត និងជំនួយ ថវិកាដើម្បីចាប់ផ្តើមមុខរបរកាត់សក់។

"ខ្ញុំបានទទួលជីវិតរបស់ខ្ញុំមកវិញ ដោយសារការគាំទ្ររបស់គម្រោង CTIP II"

បច្ចុប្បន្ននេះ គាត់រកបានប្រហែល ៩០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ ហើយឥឡូវនេះ គាត់កំពុងមានផែនការពង្រីកមុខរបររបស់គាត់ និងចិញ្ចឹមមាន់បន្ថែមទៀត។



## ព្រឹត្តិការណ៍ និងតួលេខរបស់ CTIP II
## (ឆ្នាំ២០១១-២០១៥)

### ចំនួនអ្នករស់រាន/ជនរងគ្រោះដែលត្រូវបានជួយ

- ជនរងគ្រោះដោយសារអំពើជួញដូរកម្លាំងពលកម្មចំនួន ៤៧៩ នាក់
- ជនរងគ្រោះដោយសារអំពើជួញដូរផ្លូវភេទចំនួន ៤៩ នាក់
- ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចកម្លាំងពលកម្មចំនួន ១៣៣ នាក់

### ជំនួយ និងសេវាដែលត្រូវបានផ្តល់

- ជនរងគ្រោះចំនួន ៣៥៧ នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍
- ជនរងគ្រោះចំនួន ៤៨៧នាក់បានទទួលការប្រឹក្សាយោបល់ផ្លូវចិត្ត
- ជនរងគ្រោះចំនួន ៣៥០នាក់បានទទួលការប្រឹក្សាយោបល់ផ្នែកច្បាប់
- ជនរងគ្រោះចំនួន ៧៥ នាក់ដែលត្រូវបានជួយ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងជនល្មើស
- ជនរងគ្រោះចំនួន ៣៧ នាក់បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងរបរចិញ្ចឹមជីវិត
- ជនរងគ្រោះចំនួន ១៤៩ នាក់ត្រូវបានធ្វើសមាហរណកម្ម
- ជនរងគ្រោះចំនួន ៦៨ នាក់បានទទួលជំនួយសម្រាប់ធ្វើអាជីវកម្ម និងជំនួយសម្រាប់ចាប់ផ្តើមជីវិតថ្មី

* តួលេខទាំងអស់នេះបានធ្វើបច្ចុប្បន្នភាពរហូតដល់ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៣

## យុវជនដឹកនាំជីវិតរបស់ខ្លួនៈយុទ្ធនាការជិះកង់ ក្រោមប្រធានបទចំណាកស្រុកដោយសុវត្ថិភាព

កាលពីខែមករា ឆ្នាំ២០១៤ បណ្តាញយុវជនសហគមន៍ នៃសមាគមយុវជនខ្មែរ (KYA) បានរៀបចំយុទ្ធនាការជិះកង់តាមភូមិកន្លះថ្ងៃ។ កម្មវិធីជិះកង់នេះមានការចូលរួមពី សិស្សសាលានៅឃុំរើល ស្រុកពួក ខេត្តសៀមរាប ចំនួន ៥០ នាក់។ តាមរយៈការបង្ហាត់បង្រៀន និងកញ្ចប់ថវិកាបន្តិចបន្តួចពីកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (CTIP II) យុវជនដែលត្រូវបានបណ្តុះបណ្តាលបានផ្តួចផ្តើមដោយខ្លួនឯងនូវព្រឹត្តិការណ៍នេះនៅក្នុងសហគមន៍របស់ពួកគេ។




ក្នុងអំឡុងព្រឹត្តិការណ៍នេះ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាឃុំ និងមេប៉ុស្តិ៍នគរបាលបានផ្តល់ព័ត៌មាន និងគន្លឹះសំខាន់ៗដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីរបៀបធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ឯកសារព័ត៌មានរួមជាមួយនឹងលេខទូរស័ព្ទទាន់ហេតុការណ៍ ក៏ត្រូវបានចែកជូនផងដែរ ហើយសិស្សានុសិស្សក៏ទទួលបានការលើកទឹកចិត្ត និងបំផុសគំនិតអំពីអត្ថប្រយោជន៍រយៈពេលវែងនៃការសិក្សាធៀបនឹងហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់។

ចាប់តាំងពីឆ្នាំ២០១៣ គម្រោង CTIP II ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយបណ្តាញយុវជននៃ KYA នៅក្នុងខេត្តចំនួនប្រាំមួយ ដូចជា ស្វាយរៀង ព្រៃវែង កំពង់ចាម សៀមរាប កោះកុង និងភ្នំពេញ។ បណ្តាញនីមួយៗត្រូវបានបណ្តុះបណ្តាលដោយ KYA អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព អំពើជួញដូរមនុស្ស និងអំពីរបៀបផ្សព្វផ្សាយព័ត៌មាន។ មានសកម្មភាព ជាច្រើនដែលរៀបចំឡើងដោយបណ្តាញយុវជនស្មគ្រ័ចិត្តដូចជា៖ ការពិភាក្សាក្នុងក្រុមតូច ការជជែកតទល់ ការប្រឡងប្រជែងក្នុងសហគមន៍ ការប្រគុំតន្ត្រី។ល។

នៅខែកុម្ភៈ មានបណ្តាញមួយទៀតក៏បានរៀបចំការបណ្តុះបណ្តាលមួយ ដើម្បីជួបជុំក្រុមយុវជនដែរ ហើយពួកគេបានបង្កើតផែនការផ្សព្វផ្សាយចំនួនបីសម្រាប់ចែករំលែកពត៌មាននៅក្នុងសហគមន៍ និងសាលារៀន។

## ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធឆ្លើយតបជាសារសម្លេង (IVR) របស់ CTIP II ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

នៅប្រទេសកម្ពុជា ជនចំណាកស្រុកភាគច្រើននៅតែជ្រើសរើសការធ្វើចំណាកស្រុកខុសច្បាប់ ដែលអាចធ្លាក់ទៅក្នុងស្ថានភាពកេងប្រវ័ញ្ច និងអំពើជួញដូរមនុស្ស។ គម្រោង CTIP II សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពង្រឹងដំណើរការធ្វើចំណាកស្រុកស្របច្បាប់ និង កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋចំពោះការកេងប្រវ័ញ្ច និងអំពើជួញដូរកំលាំងពលកម្ម។

ក្នុងក្របខ័ណ្ឌនេះ គម្រោង CTIP II បានសហការជាមួយកម្មវិធី SPICE ក្រោមជំនួយថវិកាពី USAID បានចាប់ផ្តើមដំណើរការប្រព័ន្ធឆ្លើយតបសារជាសម្លេងស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤។ លេខទូរស័ព្ទ៩ខ្ទង់ **០៩៥.៩៧៥.៨០៤** គឺជាលេខដែលអាចទទួលការហៅចូលដើម្បីស្តាប់សារឆ្លើយតបជាសម្លេង ស្តីពីការធ្វើចំណាកស្រុកស្របច្បាប់ និងប្រកបដោយសុវត្ថិភាព។ រាល់ការហៅពីប្រព័ន្ធ សែលកាត (Cellcard) នឹងមិនគិតថ្លៃទេ រីឯការហៅពី ប្រព័ន្ធផ្សេងទៀតនឹងត្រូវកាត់ថ្លៃធម្មតា។ ប្រព័ន្ធឆ្លើយតបជាសម្លេងនេះ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់សារសំខាន់ៗដូចជា ការងារនៅក្នុងប្រទេស ការត្រៀមខ្លួនមុនពេលចេញទៅធ្វើការនៅក្រៅប្រទេស អ្វីដែលត្រូវធ្វើ និង មិនត្រូវធ្វើនៅប្រទេសគោលដៅ និងជំនួយបន្ទាន់សម្រាប់ពលករចំណាកស្រុក។

ការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយបែបនេះ គឺជាបច្ចេកវិទ្យាដែលសមស្របមួយសម្រាប់ប្រទេសកម្ពុជា ដែលយុវជនជាង៩០ភាគរយប្រើប្រាស់ទូរស័ព្ទ។ ហើយសំឡេងនៅតែជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការប្រាស្រ័យទាក់ទងទៅកាន់អ្នកដែលពុំអាចអានអក្សរបាន (មានទូរស័ព្ទតែមួយគ្រឿងប៉ុណ្ណោះក្នុងចំណោមទូរស័ព្ទ ៤ គ្រឿង ដែលអាចប្រើប្រភេទអក្សរខ្មែរបាន)។ បច្ចុប្បន្ន សេវាផ្តល់សារជាសម្លេងនេះកំពុងធ្វើការសាកល្បង និងមានផែនការរួចហើយក្នុងការដំឡើងសមត្ថភាព និងពង្រីកសេវានេះ ដើម្បីគាំទ្រដល់ជនចំណាកស្រុក នៅក្នុងប្រទេសគោលដៅផងដែរ។



## ដៃគូរបស់ CTIP II ជួយជនរងគ្រោះឲ្យបានត្រឡប់មកផ្ទះវិញ

ពីខែមករា ដល់ខែមីនា ឆ្នាំ២០១៤ ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ៩៤ នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជា ដោយមានគាំទ្រពី CTIP II ៖ ៨៤ នាក់មកពីប្រទេសវៀតណាម (ពីខេត្តតៃនិញ និងហូជីមិញ) និង ១០ នាក់មកពីប្រទេសថៃ (ពី មណ្ឌលKretakan និង Phaya , បាងកក)។

៧២ នាក់ក្នុងចំណោមពួកគេ គឺជាកុមារ ពួកគេជាច្រើននាក់ មានអាយុក្រោម ១០ ឆ្នាំ ត្រូវបានសមាជិកគ្រួសារ ឬមេខ្យល់នាំទៅធ្វើការជាអ្នកសុំទាន និងកម្មកររោងចក្រនៅប្រទេសក្រៅ។



គម្រោង CTIPII ផ្តល់អាហារ កន្លែងស្នាក់នៅ ការប្រឹក្សាយោបល់ ការដឹកជញ្ជូន និងការពិនិត្យសុខភាពដល់ពួកគេ និងរៀបចំផែនការសមាហរណកម្មដែលសមស្របតាមតម្រូវការផ្សេងៗគ្នា។ ពួកគេមួយចំនួនត្រូវបានបញ្ជូនទៅកាន់មណ្ឌលរបស់ដៃគូរបស់គម្រោង CTIP II ដើម្បីទទួលការគាំទ្របន្ត។ ពួកគេមួយចំនួនទៀត ត្រូវបានបញ្ជូនត្រឡប់ទៅកាន់សហគមន៍ដើមរបស់ពួកគេវិញដែល គម្រោង CTIPII នឹងបន្តតាមដានសមាហរណកម្មរបស់ពួកគេ ដើម្បីបង្ការទប់ស្កាត់ហានិភ័យដែលពួកគេត្រូវបានកេងប្រវ័ញ្ច និងរំលោភបំពានជាថ្មីទៀត។

## យុត្តិធម៌ត្រូវតែមាន៖ ការឃ្លាំមើលករណីក្រុមហ៊ុនជ្រើសរើសពលករ Giant Ocean

គម្រោង CTIPII កំពុងតាមឃ្លាំមើលយ៉ាងជិតដល់លើការជំនុំជម្រះករណីក្រុមហ៊ុនជ្រើសរើសពលករ Giant Ocean Interntional Fishery Co. Ltd ជាក្រុមហ៊ុនជ្រើសរើសពលករមួយដែលបានទទួលអាជ្ញាប័ណ្ណឲ្យធ្វើការជ្រើសរើស និង បញ្ជូនពលករទៅប្រទេសជប៉ុន គូវ៉ែត ថៃ និងម៉ាឡេស៊ី។ ការជំនុំជម្រះបានចាប់ផ្តើមជាដំបូងនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤។

បន្ទាប់ពីការស៊ើបអង្កេតជាច្រើនខែ ដោយមានការគាំទ្រពីក្រុមការងារជាដៃគូនៃគម្រោង CTIP II គឺអង្គការ ជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW), មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) និង សម្ព័ន្ធខ្មែរ ជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ប្រធានក្រុមហ៊ុនជ្រើសរើសពលករនៅកម្ពុជា។

លោកស្រី Lin Li Chen ត្រូវនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ចាប់ខ្លួនក្នុងខែឧសភា ឆ្នាំ២០១៣ ពីបទនាំយកមនុស្សចេញដោយមិនស្របច្បាប់ដោយមានគោលដៅ យោងតាមមាត្រា ១០ នៃច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ យោងតាមសេចក្តីរាយការណ៍នានាបានឲ្យដឹងថា ចាប់តាំង ពីក្រុមហ៊ុនជ្រើសរើសពលករ Giant Ocean ទទួលបានអាជ្ញាប័ណ្ណឲ្យជ្រើសរើសពលករមក ក្រុមហ៊ុននេះ បានបញ្ជូនពលករនេសាទខ្មែរជាង ១.០០០នាក់ ឲ្យទៅធ្វើការលើកប៉ាល់នេសាទនៅក្នុងប្រទេសមួយចំនួនដូចជា សិង្ហបុរី ឥណ្ឌូនេស៊ី អាហ្វ្រិកខាងត្បូង ឬ សេនេហ្គាល់។ ពលករជាច្រើនទទួលរងការរំលោភបំពានផ្លូវកាយ និងការឃុំឃាំង ហើយពលករភាគច្រើនបានវិលត្រឡប់មកផ្ទះវិញដោយដៃទទេបន្ទាប់ពី បានធ្វើការយ៉ាងលំបាកលំបិនជាច្រើនឆ្នាំ លើកប៉ាល់នេសាទមក។

ក្នុងអំឡុងពេលនៃការជំនុំជម្រះ ពលករនេសាទទាំងអស់ បានចង្អុលមុខជនសង្ស័យ និង បញ្ជាក់អត្តសញ្ញាណ ប្តីរបស់នាងថាជាជនដែលបានគ្រប់គ្រងទីស្នាក់ការក្រុមហ៊ុន Giant Ocean International Fishery Co., Ltd នៅប្រទេសកម្ពុជា ហើយពួកគេបានទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្ត ដូចជា ប្រាក់ឈ្នួលដែលមិនទាន់បើក និងការទទួលរងនូវការរំលោភបំពាននានា។ គម្រោង CTIP II បានផ្តល់ការគាំទ្រដល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃសម្រាប់ជនរងគ្រោះចំនួន ៩៣នាក់ តាមរយៈអង្គការ LSCW។

ក្នុងពេលជំនុំជម្រះ សាច់ញាតិមួយចំនួនរបស់ ពលករដែលកំពុងបាត់ខ្លួននៅឡើយ បានរង់ចាំទទួលនូវភាព យុត្តិធម៌ដោយអន្ទះសាសម្រាប់មនុស្សជាទីស្រឡាញ់របស់ពួកគេដែលកំពុងមានវ័យក្មេងនៅឡើយ ហើយដែល បានបាត់ខ្លួននៅក្នុងលំហសមុទ្រ។

គម្រោង CTIP II បន្តគាំទ្រគ្រួសារ និងជនរងគ្រោះដែលពួកគេសមនឹងទទួលបានសំណងសមស្របចំពោះការខាតបង់របស់ពួកគេ។



# លេខទូរស័ព្ទសារជាសំឡេង ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ០៩៥ ៩៧៥ ៨០៤

រាល់ការហៅពីប្រព័ន្ធ Cellcard (សែលកាត) នឹងមិនគិតថ្លៃទេ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤

## ប្រសិនបើអ្នកបានជួបប្រទះ ឬធ្លាក់ក្នុងអំពើជួញដូរមនុស្ស អ្នកអាចស្វែងរកជំនួយបានតាមរយៈ លេខទំនាក់ទំនងដូចខាងក្រោម

### ក្នុងប្រទេសកម្ពុជា

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

០២៣ ៩៩ ៧៩ ១៩ ឬ ១២៨៨ (ហៅចូលដោយឥតគិតថ្លៃ)

### ការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅតាមបណ្តាខេត្ត ក្រុង

| | |
|---|---|
| ក្រុងភ្នំពេញ | ០១៧ ២៧៦ ២២២ |
| ខេត្តសៀមរាប | ០១៧ ២៥៨ ២២២ |
| ខេត្តបាត់ដំបង | ០១៧ ២៣៦ ២២២ |
| ខេត្តកំពង់ធំ | ០១៧ ២៥៤ ២២២ |
| ខេត្តបន្ទាយមានជ័យ | ០១៧ ២៦០ ២២២ |
| ខេត្តកំពង់ឆ្នាំង | ០១៧ ៣២៦ ២២២ |
| ក្រុងព្រះសីហនុ | ០១៧ ២៥៩ ២២២ |

### លេខទំនាក់ទំនងអង្គការនៅក្នុងប្រទេសកម្ពុជា

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
០៩៨ ៣៦០ ០៤៩ (ប៉ោយប៉ែត)
០៨៨ ៦៩៥ ៤១៧៨ (សៀមរាប)

អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)
០៧៧ ៤៥៥ ៥១៦

អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
០១២ ៩១៣ ១៣៨

### លេខទំនាក់ទំនងនៅក្រៅប្រទេស

ស្ថានទូតកម្ពុជា នៅប្រទេសថៃ
+៦៦ ២៩ ៥៧៥ ៨៥១

អង្គការសម្ព័ន្ធសកលប្រឆាំងអំពើជួញដូរស្ត្រី នៅប្រទេសថៃ (GAATW)
+៦៦ ២៨ ៦៤១ ៤២៧

អង្គការ LPN នៅប្រទេសថៃ
+៦៦ ៣៤ ៤៣៤ ២៦៧

ស្ថានទូតកម្ពុជា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៤ ២៥៧ ១១៥០
+៦០ ៣៤ ២៥៧ ៣៧១១

អង្គការទីណាហ្គានីតា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៧ ៧៧០ ៣៦៩១

ក្រសួងការងារ នៅប្រទេសសិង្ហបុរី (MOM)
+៦៥ ៦៤ ៣៨៥ ១២២ (សម្រាប់សំណួរទូទៅ)
+៦៥ ៦៥ ៣៨៦ ៩៣០ (សំណួរទាក់ទងនឹងគុណភាពសេវាកម្ម)

ភ្នាក់ងារពឹងពាក់សម្រាប់អ្នកបម្រើដែលស្នាក់នៅបណ្តោះអាសន្ន នៅប្រទេសសិង្ហបុរី (TWC2)
+៦៥ ៦២ ៤៧៧ ០០១

អង្គការមនុស្សធម៌សម្រាប់សេដ្ឋកិច្ចនៃការធ្វើទេសន្តប្រវេសន៍ នៅប្រទេសសិង្ហបុរី (HOME)
បណ្តាញជំនួយ២៤ម៉ោងសម្រាប់ស្ត្រី និងបុរស បំរើការងារតាមផ្ទះ:
+៦៥ ៦៣ ៤១៥ ៥២៥ (សម្រាប់ស្ត្រី)
+៦៥ ៦៣ ៤១៥ ៥៣៥ (សម្រាប់បុរស)

អង្គការវីនរ៉ក់អន្តរជាតិ ជាអង្គការមិនរកផលចំណេញ ដែលធ្វើការជាមួយប្រជាជនក្នុងសហរដ្ឋអាមេរិក និង នៅទូទាំងពិភពលោក ដើម្បីជួយដល់ជនក្រីក្រ បង្កើនឱកាសរកប្រាក់ចំណូល និងថែរក្សាធនធានធម្មជាតិអោយបានគង់វង្ស។


WINROCK INTERNATIONAL
Putting Ideas to Work

ការិយាល័យអង្គការវីនរ៉ក់នៅប្រទេសកម្ពុជា

មជ្ឈមណ្ឌលភ្នំពេញ អគារ អែហ្វ បន្ទប់លេខ ៧៨៧ មហាវិថី សុធារស រាជធានីភ្នំពេញ ទូរស័ព្ទ: +៨៥៥-២៣ ២១២ ៣៣៤/៦ ទូរសារ: +៨៥៥-២៣ ២១២ ៣៣៥
សារអេឡិចត្រូនិច: cambodiaadmin@field.winrock.org
គេហទំព័រ: www.winrock.org